# ការបង្រៀននៅសម័យទំនើបដែលទាក់ទងនឹងទង់ឥស្សរភាព

### «នៅក្នុងការចងចាំព្រះរបស់យើង»

អែលឌើរ នែល អិល អាន់ឌើរសិន (Elder Neil L. Andersen)ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖



មានមនុស្សមួយចំនួននៅលើផែនដីស្គាល់ព្រះយេស៊ូវគ្រីស្ទតិចតួច ហើយនៅផ្នែកខ្លះទៀតនៃពិភពលោកដែលព្រះនាមរបស់ទ្រង់ត្រូវបានប្រកាសរាប់សតវត្សមកហើយ តែបែរជាជំនឿលើព្រះយេស៊ូវគ្រីស្ទកំពុងតែថយចុះទៅវិញ ។ . . .

កាលដែលលោកិយមិនសូវនិយាយអំពីព្រះយេស៊ូវគ្រីស្ទ ចូរយើងនិយាយអំពីទ្រង់ឲ្យបានកាន់តែច្រើនឡើង ។ នៅពេលបុគ្គលិកលក្ខណៈពិតរបស់យើងក្នុងនាមជាសិស្សរបស់ទ្រង់ត្រូវបានបង្ហាញ នោះមនុស្សជាច្រើននៅជុំវិញយើងនឹងត្រៀមខ្លួនស្ដាប់ ។ (នែល អិល អាន់ឌើរសិន(Neil L. Andersen) «យើងជជែកគ្នាអំពីព្រះគ្រីស្ទ» Liahona *(លីអាហូណា)*, វិច្ឆិកា ២០២០,ទំព័រ ៨៨, ៩០)

### «នៅក្នុងការចងចាំ. . .សាសនារបស់យើង»

ប្រធាន ដាល្លិន អេក អូក (Dallin H. Oaks)ក្នុងគណៈប្រធានទីមួយបានបង្រៀនថា ៖



បើយើងឈប់ឱ្យតម្លៃសាសនាចក្រយើងដោយហេតុផលណាមួយ នោះយើងគំរាមកំហែងដល់ជីវិតខាងព្រលឹងវិញ្ញាណផ្ទាល់ខ្លួនយើងហើយៗជនគណនាដ៏សំខាន់ៗដែលបំបែកខ្លួនពួកគេចេញពីព្រះកាត់បន្ថយពរជ័យរបស់ទ្រង់ចំពោះប្រជាជាតិយើង។

ការចូលរួម និងសកម្មភាពនៅក្នុងព្រះវិហារមួយ ជួយយើងឲ្យក្លាយជាមនុស្សកាន់តែប្រសើរឡើង ហើយជះឥទ្ធិពលកាន់តែខ្លាំងលើជីវិតរបស់មនុស្សដទៃផងដែរ ។ នៅសាសនាចក្រ មានការបង្រៀនយើងអំពីរបៀបអនុវត្តគោលការណ៍សាសនា។ យើងរៀនពីគ្នាទៅវិញទៅមក។. . .

. . . ខ្ញុំសូមអធិស្ឋានឲ្យយើងទាំងអស់គ្នានឹងមានភាពខ្ជាប់ខ្ជួននៅក្នុងបទពិសោធន៍នៃសាសនាចក្រទាំងនេះ នៅពេលដែលយើងស្វះស្វែងរកជីវិតដ៏អស់កល្បជានិច្ចដែលជាអំណោយទានដ៏អស្ចារ្យបំផុតនៃព្រះ។ (ដាល្លិន អេក អូក(Dallin H. Oaks) «ចាំបាច់ត្រូវមានព្រះវិហារមួយ» Liahona *(លីអាហូណា)*, វិច្ឆិកា ២០២១,ទំព័រ ២៤, ២៦)

### «នៅក្នុងការចងចាំអំពីសេរីភាព . . . របស់យើង»

អែលឌើរ រ៉ូណល អេ រ៉ាសបាន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



តើអ្វីទៅជាសេរីភាពខាងសាសនា ?

វាគឺជាសេរីភាពនៃការថ្វាយបង្គំតាមគ្រប់ទម្រង់ទាំងអស់ ៖ សេរីភាពនៃការប្រមូលផ្ដុំ សេរីភាពនៃការបញ្ចេញមតិ សេរីភាពក្នុងការធ្វើសកម្មភាពលើជំនឿផ្ទាល់ខ្លួន និងសេរីភាពសម្រាប់មនុស្សដទៃដើម្បីធ្វើដូចគ្នានេះដែរ ។ សេរីភាពខាងជំនឿសាសនាអនុញ្ញាតឲ្យយើងម្នាក់ៗ ធ្វើការសម្រេចចិត្តសម្រាប់ខ្លួនយើងផ្ទាល់សម្រាប់អ្វីដែលយើងជឿ របៀបរស់នៅ និងធ្វើស្របតាមជំនឿរបស់យើង និងអ្វីដែលព្រះសព្វព្រះទ័យពីយើង ។ . . .

ខ្ញុំសូមអញ្ជើញបងប្អូនឲ្យគាំទ្រដល់បុព្វហេតុនៃសេរីភាពខាងជំនឿសាសនា ។ វាគឺជាការបង្ហាញនៃគោលការណ៍សិទ្ធិជ្រើសរើសដែលបានប្រទានមកពីព្រះ ។

សេរីភាពខាងសាសនានាំមកនូវតុល្យភាពចំពោះទស្សនវិជ្ជាប្រកួតប្រជែង ។ ភាពល្អនៃសាសនា ព្រំដែនប្រសិទ្ធភាពរបស់វា និងទង្វើប្រចាំថ្ងៃនៃសេចក្ដីស្រឡាញ់ដែលសាសនាបំផុសគំនិតឱ្យកើនឡើង នៅពេលដែលយើងការពារសេរីភាពក្នុងការបញ្ចេញមតិ និងធ្វើសកម្មភាពលើជំនឿសំខាន់ៗ។ (រ៉ូណល អេ រ៉ាសបាន(Ronald A. Rasband) «ព្យាបាល (ប្រោស)ពិភពលោក» Liahona *(លីអាហូណា)*, ឧសភា ២០២២,ទំព័រ ៩១, ៩៣)

### «នៅក្នុងការចងចាំអំពីសន្តិភាព . . . របស់យើង»

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



អង្គព្យាបាលនៃបួសគ្រប់យ៉ាង ទ្រង់ជាអង្គកែទោសកំហុសទាំងអស់ សុំឲ្យយើងធ្វើការជាមួយទ្រង់នៅក្នុងកិច្ចការលំបាកនៃការផ្សះផ្សាក្នុងពិភពលោក ដែលពុំកេឃើញភាពសុខសាន្តតាមរបៀបណាផ្សេងទៀតឡើយ ។ . . .

. . . នោះខ្ញុំសូមឲ្យបងប្អូនធ្វើជាអ្នកផ្សះផ្សាគេ—ឲ្យស្រឡាញ់ភាពសុខសាន្ត ឲ្យស្វែងរកភាពសុខសាន្ត ឲ្យបង្កើតភាពសុខសាន្ត ឲ្យរីករាយនឹងភាពសុខសាន្ត ។ ខ្ញុំសូមអំពាវនាវ ក្នុងព្រះនាមព្រះអង្គម្ចាស់នៃសេចក្ដីសុខ(សន្តិភាព)។ (ជែហ្វ្រី អរ ហូឡិន(Jeffrey R. Holland) «ការងារបម្រើនៃការផ្សះផ្សា» Liahona *(លីអាហូណា)*, វិច្ឆិកា ២០១៨,ទំព័រ ៧៩)

### «នៅក្នុងការចងចាំ[គ្រួសារ]. . .របស់យើង»

ស៊ិស្ទើរ បូនី អិល អូស្កាសិន អតីតប្រធានយុវនារីទូទៅបានបង្រៀន ៖



មនុស្សគ្រប់គ្នា មិនថាមានស្ថានភាពអាពាហ៍ពិពាហ៍យ៉ាងណា ឬមានកូនប៉ុន្មានទេ អាចធ្វើជាអ្នកការពារផែនការរបស់ព្រះអម្ចាស់ ដែលបានពិពណ៌នានៅក្នុងសេចក្តីប្រកាសអំពីគ្រួសារបាន ។ បើវាគឺជាផែនការរបស់ព្រះអម្ចាស់ វាគួរតែជាផែនការរបស់យើងដែរ ! . . .

. . . សូមឲ្យយើងជួយកសាងរាជាណាចក្រព្រះដោយការក្រោកឈរឡើងយ៉ាងក្លាហាន ហើយធ្វើជាអ្នកការពារអាពាហ៍ពិពាហ៍ ភាពជាឪពុកម្ដាយ និងផ្ទះសម្បែង។ ព្រះអម្ចាស់ត្រូវការឲ្យយើងក្លាហាន ខ្ជាប់ខ្ជួន និងក្លាយជាអ្នកចម្បាំងដ៏រឹងមាំដែលនឹងការពារផែនការរបស់ទ្រង់ ហើយបង្រៀនមនុស្សជំនាន់ក្រោយៗអំពីសេចក្តីពិតរបស់ទ្រង់។ (បូនី អិល អូស្ការសិន(Bonnie L. Oscarson) «អ្នកការពារសេចក្តីប្រកាសរបស់ក្រុមគ្រួសារ» Liahona *(លីអាហូណា)*, ឧសភា ២០១៥,ទំព័រ ១៥, ១៧)

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៣ by Intellectual Reserve, Inc. All rights reserved. PD60013873_258_332-teacher_handout-1